**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៦-១០៦ ធ.ក

លិខិតចូល
ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ2006

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- តាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦

## ស ម្រេ ច

**ប្រការ ១.-**

បង្កើតក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- លោកជំទាវ តាល់ ណែអ៊ីម | អគ្គនាយកធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- លោក ផាន់ ហូរ | អគ្គនាយករងធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣- លោក ណាត់ថាវុធ រះកាណាន់ | អគ្គនាយកធនាគារកម្ពុជាពាណិជ្ជចំកាត់ | សមាជិក |
| ៤- លោក ផាន យិង ចុង | អគ្គនាយកធនាគារកម្ពុជាសាធារណៈចំកាត់ | សមាជិក |

៥- លោក វ៉ាន់ ឆារស៍ ជួន អគ្គនាយករងធនាគារកាណាឌីយ៉ា ក.អ សមាជិក

៦- លោក អូវ ស៊ួន វិច អ្នកគ្រប់គ្រងជាន់ខ្ពស់ធនាគារសហពាណិជ្ជ ក.អ សមាជិក

៧- លោក អ៊ិន ស៊ីផាន់ នាយកឥណទានធនាគារអេស៊ីលីដា ភីអិលស៊ី សមាជិក

**ប្រការ ២.-**

ក្រុមប្រឹក្សាភិបាលនៃប្រការ១ ខាងលើមានមុខងារ និងភារកិច្ចដូចខាងក្រោម ÷

- ត្រួតពិនិត្យលើប្រតិបត្តិការ និងការអនុវត្តន៍របស់ភ្នាក់ងារដើម្បីធានានូវសុវត្ថិភាពនៃមូលដ្ឋានទិន្នន័យព័ត៌មានឥណទាន ប្រសិទ្ធភាព និងភាពសមស្របនៃវិធានការដែលត្រូវប្រកាន់យកដោយទីភ្នាក់ងារ និងការគោរពតាមក្រមប្រតិបត្តិរបស់សមាជិក
- ត្រួតពិនិត្យលទ្ធភាពនៃការបំពានទៅលើប្រកាស និងក្រមប្រតិបត្តិតាមរយៈការធ្វើសវនកម្មទៀងទាត់ និងតាមការជាក់ស្តែង
- រៀបចំបែបបទស្តីពីការដាក់ទណ្ឌកម្ម និងតារាងពិន័យចំពោះរាល់ការរំលោភលើប្រកាស និងក្រមប្រតិបត្តិ បន្ទាប់ពីទទួលបានការអនុម័តលើតារាងដំបូង (ឧបសម្ព័ន្ធ២ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន) ពីធនាគារជាតិនៃកម្ពុជា ។ ទណ្ឌកម្ម និងតារាងពិន័យ អាចត្រូវបានកែតម្រូវដោយក្រុមប្រឹក្សាភិបាល នៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ ទណ្ឌកម្ម និងតារាងពិន័យ ដែលបានកែតម្រូវដោយក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវមានប្រសិទ្ធភាពអនុវត្តដូចតារាងអនុម័តដំបូងដោយធនាគារជាតិនៃកម្ពុជា និងត្រូវផ្សព្វផ្សាយឱ្យធនាគាជាសមាជិកដឹងជាបន្ទាន់
- កំណត់សោហ៊ុយដែលសមាជិកនីមួយៗត្រូវចូលរួម ដើម្បីដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

**ប្រការ ៣.-**

ប្រធានក្រុមប្រឹក្សាភិបាលមានសិទ្ធិអញ្ជើញសមាសជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ និងធ្វើការងារតាមការចាំបាច់ ។ សមាសភាពក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវគ្រប់កិច្ចការដែលប្រធានប្រគល់ឱ្យ ។

**ប្រការ ៤.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា និងសាមីជននៃប្រការ១ ខាងលើ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៦

**ទេសាភិបាល**

ជា ចាន់តូ

**កន្លែងទទួល :**

- ដូចប្រការ ១ និងប្រការ ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"